**សង្ខេបពត៌មាន**
**7/2020**

## សភាពាណិជ្ជកម្មអឺរ៉ុបនិងGMACទទូចឲEUពន្យាពេលដកEBAខណៈរដ្ឋរឹងត្អឹងមិនសុំការអនុគ្រោះ

ភ្នំពេញ៖ ស្ថាប័ន៣ បានចេញសេចក្ដីថ្លែងការណ៍រួមគ្នាម្ដងទៀត ដោយទទូចឲសហភាពអឺរ៉ុបពន្យាពេលដកប្រព័ន្ធអនុគ្រោះពន្ធគ្រប់យ៉ាងលើកលែងតែអាវុធ (EBA)ពីកម្ពុជា ដែលគ្រោងអនុវត្តនៅខែសីហា ឆ្នាំ២០២០ខាងមុខ។

ទាំងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សមាគមស្បែកជើងកម្ពុជា ( CFA) និងសភាពាណិជ្ជកម្មអឺរ៉ុប (EROCHAM) សុទ្ធតែយល់ឃើញថា សហភាពអឺរ៉ុប មិនគួរដកEBA ស្របពេលដែលកម្ពុជាកំពុងរងផលប៉ះពាល់ដោយសារបញ្ហាកូវីដ-១៩នោះទេ។

សេចក្ដីថ្លែងការណ៍រួមគ្នានេះ បានបញ្ជាក់ថា កម្មករប្រមាណ១៥ម៉ឺននាក់ដែលក្នុងនោះភាគច្រើនស្ត្រីកំពុងប្រឈមមុខនឹងបញ្ហាជីវភាពក្រោយរោងចក្រប្រមាណ៤00 បានព្យួរការងារដោយសារវិបត្តិកូវីដ-១៩ ដូច្នេះការអនុវត្តនីតិវិធីប្រព័ន្ធអនុគ្រោះពន្ធ EBA ខាងមុខនេះនឹងធ្វើឲកម្ពុជាកាន់តែប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរថែមទៀត។

លោក បេន កៅ បានបញ្ជាក់ដូច្នេះថា៖ “ រោងចក្រនិងកម្មកររបស់យើងបានរោងគ្រោះយ៉ាងខ្លាំងពីការរីករាលដាលជំងឺកូវីដ-១៩ ហើយកម្មករជាច្រើននាក់កំពុងព្យាយាមរស់រហូតទាល់តែមានតំម្រូវការផលិតផលនេះឡើងវិញ ដោយសង្ឃឹមថានឹងមានដំណើរល្អនៅក្រោយឆ្នាំ២០២០។ ការបំផ្លាញលើកទី២ដែលរោងចក្រភាគច្រើននឹងមិនឈរជើងបាន” ។

ក្រសួងពាណិជ្ជកម្មមិនបានដាក់លិខិតទៅគណៈកម្មការអឺរ៉ុបដើម្បីសុំការយោគយល់លើការអនុវត្តដក EBA ពីកម្ពុជាឡើយ ដោយអនុវត្តតាមប្រសាសន៍របស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានបញ្ជាក់ជំហរច្បាស់ថា កម្ពុជាមិនយកអធិបតេយ្យភាព ទៅដូរនឹង EBA ទេ។

សូមរម្លឹកថា គណៈកម្មការអឺរ៉ុប បានសម្រេចដក EBA ២0 ភាគរយ ពីកម្ពុជា កាលពីដើមខែកុម្ភៈ ឆ្នាំ២0២0។ បើគ្មានការប្រែប្រួលនោះទេ សល់តែ២ខែទៀតប៉ុណ្ណោះ គឺនៅខែ សីហា ឆ្នាំ២0២0 សេចក្តីសម្រេចនេះនឹងចូលជាធរមាន វាមានន័យថា ចាប់ពីខែសីហា ឆ្នាំ២0២0ទៅកម្ពុជា សេចក្តីសម្រេចនេះនឹងចូលជាធរមាន។ វា មានន័យថា ចាប់ពីខែសីហា ឆ្នាំ២0២0ភាគរយ ពេលនាំចូលទៅទីផ្សារអឺរ៉ុប៕

ថ្មីៗ 1/7/20

## ក្រសួងមិនឲរោងចក្រ-សហគ្រាសដែលបិទព្រោះវិបត្តិសេដ្ឋកិច្ចទូទាត់សំណងដល់កម្មករឡើយ

ភ្នំពេញ៖ មន្ត្រីក្រសួងការងារ និងបណ្ឌិតបណ្ឌិតវិជ្ជាជីវៈអះអាងថា បន្ទាប់ពីបិទឬព្យួរការងាររយៈពេល២ខែ ដោយសារការលំបាកណាមួយ ម្ចាស់រោងចក្រនិងម្ចាស់សហគ្រាសមានមូលហេតុត្រឹមត្រូវលើការលុបកិច្ចសន្យាការងារដោយមិនចាំបាច់ទូទាត់ "ប្រាក់សងជំងឺចិត្ត" និង "ប្រាក់បំណាច់ទូទាត់ជួសការឲដំណឹងមុន" ដល់កម្មករនិយោជិតឡើយ។ មេសហជីពមិនគាំទ្រនោះទេ ចំពោះការបកស្រាយនេះហើយយល់ថា ក្រសួងការងារហាក់បីដូចជាជួយសម្រាលបន្ទុកដល់និយោជក ដោយមិនឃើញទុក្ខលំបាករបស់កម្មករ។

លិខិតរបស់លោក អ៊ុក ចាន់ធូ ប្រធាននាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ ចេញនៅថ្ងៃទី២៩ ខែមិថុនា បញ្ជាក់ថា៖ " ផលលំបាកផ្នែកសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរនៅតាមបណ្ដារោងចក្រ...ដូចជាការលុបការបញ្ជាទិញទាំងស្រុង ការផ្អាកការទទួលទិញ-លក់ អាចត្រូវបានចាត់ជាមូលហេតុត្រឹមត្រូវក្នុងការរំលាយកិច្ចសន្យាការងារ បន្ទាប់បីព្យួរកិច្ចការងារ"។

លោក អាត់ ធន់ ប្រធានសហជីពសហភាពការងារកម្ពុជា ប្រាប់សារព័ត៌មានថ្មីៗតាមទូរសព្ទថា ការបកស្រាយរបស់ក្រសួងការងារខាងលើនេះធ្វើឲបាត់បង់ប្រយោជន៍កម្មករយ៉ាងខ្លាំង ខណៈកម្មករកំពុងរងគ្រោះ ស្ទើរគ្មានលទ្ធភាពផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃទៅហើយ។ លោកថ្លែងថា៖ " បើក្រសួងបកស្រាយបែបនេះ កម្មករនឹងបាត់បង់ប្រយោជន៍។ ក្រសួងគិតគូរពីនិយោជកច្រើន មិនឃើញការលំបាកដល់កម្មករ"។

លោកបន្តថា៖ " នៅពេលអនុញ្ញាតឲរោងចក្រព្យួរ ហើយលុបកិច្ចសន្យាការងារ ធ្វើឲកម្មករបាត់ប្រាក់សងជំងឺចិត្តមួយហើយ នៅពេលរោងចក្របិទ ភាគីម្ចាស់រោងចក្រនឹងមិនទូទាត់ប្រាក់ជូនដំណឹងទៀត"៕

ថ្មីៗ 1/7/20

## នាយករដ្ឋមន្ត្រីឯកភាពឲសម្រាកពីថ្ងៃទី១៧ដល់ថ្ងៃទី២១សីហាជំនួសថ្ងៃចូលឆ្នាំដែលមិនបានឈប់

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក អូន ព័ន្ធមុនីរ័ត្ន ស្នើឲសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន ពិនិត្យនិងដាក់ចេញថ្ងៃឈប់សម្រាក៥ថ្ងៃគឺពីថ្ងៃទី១៧ ដល់ថ្ងៃទី២១ ខែ សីហា ឆ្នាំ២០២០ ដើម្បីសងថ្ងៃឈប់ចូលឆ្នាំខ្មែរដែលរដ្ឋាភិបាលហាមពលរដ្ឋឈប់សម្រាក ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩។ សម្ដេចនាយករដ្ឋមន្ត្រីបានចារយល់ព្រមលើសំណើរនេះហើយ។

លោក អូន ព័ន្ធមុនីរ័ត្ន បានស្នើសំណើរនេះទៅសម្ដេចនាយករដ្ឋមន្ត្រីជាអ្នកសម្រេច ក្រោយពីបើកកិច្ចប្រជុំជាមួយនឹងសមាគមកាត់ដេរកម្ពុជា សហព័ន្ធទេសចរណ៍ សភាពាណិជ្ជកម្មកម្ពុជា និងអ្នកពាក់ព័ន្ធផ្សេងទៀត។

លោក ជម្រាបសម្តេចថា ការយកថ្ងៃទី១៧-២១ ខែសីហានេះ ជាថ្ងៃសងឈប់សម្រាកមួយខែនៃពិធីបុណ្យភ្ជុំបិណ្ឌ ដែលនឹងប្រព្រឹត្តឡើងនៅថ្ងៃទី១៦-១៨ ខែកញ្ញា។ ជាពិសេសជាថ្ងៃដែលកម្មករ កម្មការិនី ទទួលបានប្រាក់ខែមុនថ្ងៃឈប់សម្រាក ដែលអាចឲពួកគេមានលទ្ធភាពក្នុងការធ្វើដំណើរកំសាន្តនានា។

បើតាមរដ្ឋមន្ត្រីសេដ្ឋកិច្ចរូបនេះ ថ្ងៃឈប់នៅខែសីហា នោះ ក៏ជាពេលវេលាមួយ ដែលសហគ្រាសបញ្ចប់ចង្វាក់ផលិតកម្មនិងអាចនាំចេញទំនិញទៅតាមការបញ្ជា នៅមុនថ្ងៃទី១២ ខែសីហា ដែលការហិរញ្ញប្បទានត នៃការចូលជាធរមាននៃការព្យួរប្រព័ន្ធអនុគ្រោះពន្ធលើទំនិញលើកលែងតែអាវុធ។

លោករដ្ឋមន្ត្រី ក៏បានស្នើសុំថ្ងៃឈប់សម្រាកនោះជាថ្ងៃពន្យាពេលនៃការដាក់លិខិតប្រកាសពន្ធសម្រាប់ប្រចាំខែសីហា ព្រមទាំងស្នើឲក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រសួងសាធារណការ អាជ្ញាធរដែនដី រួមទាំងអ្នកពាក់ព័ន្ធផ្សេងទៀត សហការពង្រឹងការអនុវត្ត និងព្យួរផ្សាយពីវិធានការទប់ស្កាត់ជំងឺកូវីដ ១៩ផងដែរ៕

ថ្មីៗ 13/7/20

## ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលចុះសិក្សាពីស្ថានភាពកម្មករពីការរងផលប៉ះពាល់ដោយកូវីដ-១៩

ភ្នំពេញ៖អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមានៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះសិក្សាស្រាវជ្រាវពីស្ថានភាពជីវភាពរស់នៅរបស់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ចំពោះពួកគេ។

មេសហជីពបង្ហាញការគាំទ្រលើការចុះសិក្សាស្រាវជ្រាវនេះនឹងជួយដល់កម្មករឬវិស័យឯកជន?

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃ ៣១ កក្កដា ឆ្នាំ ២០២០ នឹងចុះអង្កេត និងសិក្សាស្រាវជ្រាវក្នុងរោងចក្រ តាមបណ្តារាជធានី-ខេត្ត។

ប្រធានសហព័ន្ធសហជីពកម្ពុជា លោកស្រី យ៉ាង សុភ័ណ្ឌ បង្ហាញជំហរថា ភាគីសហជីពគាំទ្រលើកិច្ចសន្យាពីស្ថានភាពរបស់កម្មករដែលរងផលប៉ះពាល់នៅអំឡុងពេលកូវីដ-១៩នេះ។ ប៉ុន្តែចំណុចសំខាន់បំផុត លោកស្រី បានចោទជាសំណួរថា តើគោលបំណងនៃការចុះសិក្សានេះ គឺដើម្បីជួយដល់កម្មករឬជួយដល់វិស័យឯកជន?

លោកស្រីអះអាងថា បើរដ្ឋាភិបាលប្រើការសិក្សាស្រាវជ្រាវជួយដល់កម្មករគឺជារឿងល្អ ប៉ុន្តែបើធ្វើឲបាត់បង់ប្រយោជន៍របស់កម្មករគឺជារឿងដែលអាក្រក់មើល។

មេសហាជីពរូបនេះដែលបានឆ្លើយឆ្លងជាមួយសារព័ត៌មានថ្មីៗ តាមតេឡេក្រាមដែរនោះ ថ្លែងដូច្នេះថា៖ “ យើងគាំទ្រការសិក្សានេះ ប៉ុន្តែយើងត្រូវមើលពីគោលបំណងសំខាន់ដែលសិក្សាស្រាវជ្រាវវិញក្នុងគោលបំណងយកទៅប្រើយ៉ាងណា ជួយជាប្រយោជន៍ដល់វិស័យឯកជន? នេះ ដែលត្រូវគិត បើសម្រាប់ជួយកម្មករគឺជារឿងមួយល្អនិងជាកាតព្វកិច្ចរបស់រដ្ឋ” ។

អ្នកស្រីបន្តថា៖ “ បើសិនណាការសិក្សានេះ សិក្សាស្រាវជ្រាវហើយ យកទៅជជែកនៅគណកម្មការក្រុមប្រឹក្សាការងារឬពេលដែលយើងជជែកគ្នាពីប្រាក់ឈ្នួលរបស់កម្មករមិនអាចតំឡើងបាននៅឆ្នាំក្រោយនេះ វាជាចំណុចអាក្រក់មើល ដោយរដ្ឋមិនបានការពារសិទ្ធិប្រយោជន៍របស់កម្មករទេ បែរជាជួយដល់វិស័យឯកជនទៅវិញ” ៕

ថ្មីៗ 22/7/20

## វិវាទកម្មករនិងថៅកែ៖ កម្មករវ៉ាយអូលែត ទន្ទឹងរងចាំការជួយអន្តរាគមន៍ពីសម្តេច ហ៊ុន សែន

**ភ្នំពេញ៖ កម្មករ បម្រើការងារនៅរោងចក្រ វ៉ាយអូលែត ( VIOLET APPAREL CAMBODIA CO,.LTD)** ទន្ទឹងរងចាំការជួយអន្តរាគមន៍ពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទាប់ពីយកញត្តិទៅដាក់ខុទ្ទកាល័យសម្តេច ខណៈពួកគាត់ គ្មានការងារធ្វើ ហើយភាគច្រើនសុទ្ធតែអ្នកមានវ័យចំណាស់។

នៅព្រឹកថ្ងៃទី២៩ ខែកក្កដា ម្សិលមិញ កម្មករបានដាក់ញត្តិជូនសម្តេច ហ៊ុន សែន ដើម្បីទសុំជួយដោះស្រាយថៅកែរោងចក្រទូទាត់ប្រាក់សំណងអតីតភាពការងារ ប្រាក់ជូនដំណឹង ប្រាក់បំណាច់ឆ្នាំ ប្រាក់ខែចុងក្រោយ និងអត្ថប្រយោជន៍ផ្សេងទៀតតាមផ្លូវច្បាប់ បន្ទាប់ពីរោងចក្របិទទ្វារកាលពីថ្ងៃទី១ ខែកក្កដា។ លើសពីនេះ ពួកគាត់គឺស្នើសុំក្រសួងការងារលុបចោលសេចក្តីបំភ្លឺរបស់ប្រធាននាយកដ្ឋានអធិការកិច្ចការងារដែលកាត់អត្ថប្រយោជន៍២ចំណុចចេញ គឺប្រាក់សងជំងឺចិត្ត និងប្រាក់ជូនដំណឹងពីការបិទរោងចក្រ។

លោកស្រី អ៊ុង ចាន់ធឿន តំណាងកម្មករវ៉ាយអូលែត អះអាងក្រុមកម្មករ កំពុងទន្ទឹងរងចាំការឆ្លើយតបពីខាងខុទ្ទកាល័យសម្តេច ដែលបានសន្យាថាពីរថ្ងៃទៀតនឹងឆ្លើយតបវិញ លើញត្តិដែលបានដាក់ទៅ។ លោកស្រីថ្លែងថា៖ “ពេលយកញត្តិទៅដាក់ អ្នកនៅខុទ្ទកាល័យសម្តេច បានទទួលតំណាងជួបប្រមាណ២ម៉ោង បានរៀបចំទំព្ទកខ្ញុំសរសេរបែបបទត្រូវតាមនីតិវិធីឡើងវិញ ហើយសន្យាពីរថ្ងៃទៀតនឹងឆ្លើយតបវិញ។

ការប្រមូលផ្តុំគ្នាទាមទារសុំឲមានអន្តរាគមន៍លើវិវាទរបស់កម្មកររោងចក្រវ៉ាយអូលែតនិងថៅកែនេះគឺជាលើកទី៤ហើយ ប្រសិនបើគ្មានដំណោះស្រាយសមស្របទេ លោកស្រី ចាន់ធឿន អះអាងថា ក្រុម

កម្មករនឹងបន្តការទាមទារទៀត។ ប៉ុន្តែលោកស្រី មិនទាន់លម្អិតថានឹងត្រូវធ្វើបែបណា ដោយរង់ចាំពិភាក្សាបន្ត។

រោងចក្រវ៉ាយអូលែតមានកម្មករជាង១ពាន់នាក់ ហើយភាគច្រើនបានធ្វើការងារនៅទីនោះអស់រយៈពេលជាង១០ឆ្នាំហើយ។ មកដល់ពេលនេះពួកគេមានជំយជាង៣០ទៅ៤០ឆ្នាំ ដែលពិបាករកការងារថ្មីធ្វើណាស់ ខណៈម្ចាស់រោងចក្រមិនបានទូទាត់ប្រាក់អត្ថប្រយោជន៍ផ្សេងៗដល់ពួកគាត់សម្រាប់ជាដើមទុននិងទ្រទ្រង់ជីវភាពនៅអំឡុងពេលខ្វះខាត។

ប្រធានរដ្ឋបាលនៃរោងចក្រវ៉ាយអូលែត លោក ប៉ូល សំណាង ប្រាប់សារព័តមានថ្មីៗថា ភាគីរោងចក្របានទូទាត់ប្រាក់អត្ថប្រយោជន៍តាមផ្លូវច្បាប់ឲកម្មកររួមហើយ ប៉ុន្តែមានតែកម្មករជាង៨០០នាក់ដែលទទួលយកសំណង។ លោកបញ្ជាក់ថា ប្រាក់អត្ថប្រយោជន៍ដែលភាគីរោងចក្រទូទាត់តាមច្បាប់រួមមានប្រាក់អតីតភាពការងារ ប្រាក់បំណាច់ឆ្នាំ ប្រាក់ខែចុងក្រោយ និងសម្រាប់អ្នកមានផ្ទៃពោះ។

រោងចក្រនេះបានព្យួរការងារកម្មករ ២ខែ គឺនៅខែឧសភា និងមិថុនា។ នៅថ្ងៃទី១ កក្កដា ដល់ថ្ងៃចូលធ្វើការ ក៏ត្រូវតំណាងថៅកែរោងចក្រប្រាប់ថាក្ស័យធនបណ្ដាលមកពីវិបត្តិកូវីដ-១៩។ ថៅកែមិនបានទូទាត់ប្រាក់អត្ថប្រយោជន៍គ្រប់ចំនួនតាមច្បាប់ការងារឲកម្មករឡើយ ទើបបណ្ដាលឲកម្មករផ្អះការតវ៉ាចាប់តាំងពីថ្ងៃទី១កក្កដា ស្នើឲមានដំណោះស្រាយដល់បច្ចុប្បន្ន៕

ថ្មីៗ 30/7/20

RFA 30/7/20